DHCS
CALIFORNIA DEPARTMENT OF HEALTH CARE SERVICES
Michelle Baass | Director

Medi-Cal

ជូនចំពោះសមាជិក Medi-Cal

ថ្ងៃទី 31 ខែសីហា ឆ្នាំ 2026

លិខិតនេះប្រាប់អ្នកអំពីច្បាប់សហព័ន្ធថ្មីពីរដែលសភា និងប្រធានាធិបតី Trump បានបង្កើតឡើង។
ច្បាប់ទាំងនេះនឹងប៉ះពាល់ដល់អ្នកនៅឆ្នាំក្រោយ (ក្នុងឆ្នាំ **2027**) ហើយត្រូវបានហៅថា៖

ច្បាប់ស្តីពីការចូលរួមការងារ និងសហគមន៍ និង**ច្បាប់បន្តជាថ្មីរយៈពេល 6 ខែ។**

**យើងផ្តល់ព័ត៌មានទៅអ្នកឥឡូវនេះ ប៉ុន្តែច្បាប់ទាំងនេះនឹងមិនមានប្រសិទ្ធិភាពរហូតដល់ខែមីនា ឆ្នាំ 2027។
អ្នកនឹងទទួលបានព័ត៌មានបន្ថែមអំពីច្បាប់ទាំងនេះ។**

ច្បាប់ស្តីពីការចូលរួមការងារ និងសហគមន៍

**ច្បាប់នេះចែងថា មនុស្សពេញវ័យ អាយុ 19-64 ឆ្នាំ នឹងត្រូវទៅធ្វើការ ធ្វើការងារស្ម័គ្រចិត្ត ទៅសាលារៀន
ចូលរួមកម្មវិធីបណ្តុះបណ្តាលការងារ ឬមានប្រាក់ចំណូល ដើម្បីបន្តទទួលបាន Medi-Cal។**

អ្នកអាចត្រូវបាន<u>បានលើកលែង</u>ពីច្បាប់នេះ ក្នុងករណីដែលអ្នក៖

- មានស្ថានភាពសុខភាពធ្ងន់ធ្ងរ ស្មុគស្មាញ ឬបន្តមានស្ថានភាពសុខភាពដែលរារាំងអ្នកមិនឱ្យបំពេញតាមច្បាប់នេះ។
- មានស្ថានភាពជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ដែលរារាំងអ្នកមិនឱ្យបំពេញតាមច្បាប់នេះ។
- មានផ្ទៃពោះ ឬធ្លាប់មានផ្ទៃពោះក្នុងរយៈពេល 12 ខែចុងក្រោយ ឬមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ការថែទាំក្រោយសម្រាលកូន។
- ជាអ្នកថែទាំជនពិការ ឬមានស្ថានភាពសុខភាព ឬសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ។
- មានពិការភាពដែលរារាំងអ្នកមិនឱ្យបំពេញតាមច្បាប់នេះ។
- ការប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹងលើសកម្រិត ឬខុសប្រក្រតី កំពុងស្ថិតក្នុងការព្យាបាល ឬត្រូវបានស្នើសុំឱ្យចូលរួមការព្យាបាល។
- ជាអតីតយុទ្ធជនដែលមានពិការភាពពេញលេញ (ទាំងស្រុង)។

- ជាឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំកុមារដែលមានអាយុ 13 ឆ្នាំ ឬក្មេងជាងនេះ។
- កំពុងបំពេញតាមលក្ខខណ្ឌតម្រូវការងារ CalWORKs។
- កំពុងទទួលបាន CalFresh ហើយមិនត្រូវបានលើកលែងពីកម្មវិធីការងារ CalFresh ទេ។
- កំពុងជាប់ពន្ធនាគារ ឬជាប់ឃុំ។
- ស្ថិតនៅក្នុងការថែទាំចិញ្ចឹមនៅថ្ងៃខួបកំណើតអាយុ 18 ឆ្នាំរបស់អ្នក ហើយមានអាយុក្រោម 26 ឆ្នាំ។
- ជាជនជាតិដើមអាមេរិក ឬជនជាតិដើមអាឡាស្កា។

ប្រសិនបើគ្មានចំណុចណាមួយខាងលើត្រូវនឹងអ្នកអំឡុងខែដែលអ្នកបន្តជាថ្មីទេ **អ្នកអាចបំពេញតាមច្បាប់ ហើយអាចរក្សា Medi-Cal បាន ប្រសិនបើអ្នកបំពេញតាមចំណុចណាមួយខាងក្រោមក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះចាប់តាំងពីការបន្តជាថ្មីចុងក្រោយរបស់អ្នក៖**

- អ្នកមានអាយុក្រោម 19 ឆ្នាំ។
- អ្នកមានសិទ្ធិទទួលបាន ឬបានចុះឈ្មោះក្នុង Medicare Part A ឬបានចុះឈ្មោះក្នុង Medicare Part B។
- អ្នកត្រូវបានដោះលែងពីពន្ធនាគារ ឬជាប់ឃុំក្នុងរយៈពេល 90 ថ្ងៃចុងក្រោយ។
- អ្នកបានទទួលការថែទាំនៅក្នុងមន្ទីរពេទ្យ មណ្ឌលថែទាំ ឬមណ្ឌលសុខភាពផ្លូវចិត្ត។
- អ្នកបានធ្វើដំណើរចេញពីតំបន់រស់របស់អ្នក ដើម្បីទទួលបានការព្យាបាលដោយសារស្ថានភាពសុខភាពធ្ងន់ធ្ងរ។
- អ្នករស់នៅក្នុងខោនធីដែលមានអត្រាគ្មានការងារធ្វើខ្ពស់ ឬនៅក្នុងខោនធីដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយធម្មជាតិសហព័ន្ធ។ ប្រសិនបើចំណុចណាមួយក្នុងចំណោមនេះត្រូវនឹងខោនធីរបស់អ្នក យើងនឹងធ្វើការជូនដំណឹងមួយផ្សេងទៀតទៅអ្នក។
- អ្នកត្រូវបានលើកលែងដោយសារហេតុផលណាមួយខាងលើដែលបានបង្ហាញនៅលើទំព័រទី 1។

យើងប្រហែលជាប្រើប្រាស់ព័ត៌មានដែលយើងមានរួចហើយអំពីអ្នក ដើម្បីកំណត់ថាតើអ្នកបំពេញតាមហេតុផលមួយ ឬច្រើនដែលបានបង្ហាញខាងលើឬអត់។ បើយើងអាចធ្វើបែបនេះបាន អ្នកនឹងទទួលបានការជូនដំណឹងមួយដែលបញ្ជាក់ថាអ្នកត្រូវបានលើកលែងពីច្បាប់ស្តីពីការងារ និងការចូលរួមសហគមន៍។ ការជូនដំណឹងនេះក៏នឹងចែងផងដែរថា អ្នកអាចរក្សា Medi-Cal របស់អ្នក ហើយអ្នកមិនចាំបាច់ចាត់វិធានការអ្វីបន្ថែមទៀតទេ។

ប្រសិនបើយើងមិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីកំណត់ដោយស្វ័យប្រវត្តិថាអ្នកបំពេញតាមហេតុផលណាមួយខាងលើទេ អ្នកនឹងមានឱកាសផ្តល់ព័ត៌មានដែលអាចលើកលែងអ្នកពីច្បាប់នេះ។

វិធីដែលអ្នកអាចបំពេញតាមច្បាប់នេះ

ប្រសិនបើហេតុផលណាមួយដែលបានបង្ហាញខាងលើមិនត្រូវនឹងអ្នកនៅពេលអ្នកបន្ត Medi-Cal របស់អ្នកទេ អ្នកអាចបំពេញតាមច្បាប់នេះដោយ**វិធីណាមួយ ឬការរួមបញ្ចូលគ្នានៃចំណុចខាងក្រោម៖**

- **មានប្រាក់ចំណូលពីប្រភពណាមួយយ៉ាងហោចណាស់ $580 (មុនបង់ពន្ធ)**
  ក្នុងខែណាមួយចាប់តាំងពីការបន្តជាថ្មីចុងក្រោយរបស់អ្នក។
  - អ្នកដែលមានម៉ោងធ្វើការផ្លាស់ប្តូរញឹកញាប់ ឬអ្នកដែលមានការងារតាមរដូវ អាចរកចំណូលជាមធ្យមយ៉ាងហោចណាស់ $580 ក្នុងមួយខែពីប្រភពណាមួយក្នុងរយៈពេល 6 ខែ។
- ធ្វើការគ្រប់ប្រភេទការងារ ធ្វើការស្ម័គ្រចិត្ត ធ្វើសេវាសហគមន៍ ឬចូលរួមកម្មវិធីបណ្តុះបណ្តាលការងារដោយមានចំនួនសរុបចូលគ្នាយ៉ាងតិច **80 ម៉ោងក្នុងខែចាប់តាំងពីការបន្តជាថ្មីចុងក្រោយរបស់អ្នក។**
- **ទៅសាលារៀនយ៉ាងហោចណាស់ក្រៅម៉ោងក្នុងខែ ចាប់តាំងពីការបន្តជាថ្មីចុងក្រោយរបស់អ្នក។**
  - អ្នកដែលទៅសាលារៀនតិចជាងក្រៅម៉ោងអាចបូកម៉ោងសិក្សា និងសកម្មភាពសាលារបស់ពួកគេជាមួយនឹងការងារ សេវាសហគមន៍ ឬការបណ្តុះបណ្តាលការងារ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវ 80 ម៉ោង។

ដំឡូរនេះ អ្នកមិនចាំបាច់ធ្វើអ្វីទេ។ អ្នកត្រូវតែចាប់ផ្តើមបំពេញតាមច្បាប់នេះចាប់ពីឆ្នាំ 2027។ មុនដាច់ឆ្នាំនេះ អ្នកនឹងទទួលបានព័ត៌មានបន្ថែមអំពីការងារ ការងារស្ម័គ្រចិត្ត សេវាសហគមន៍ និងឱកាសសិក្សាដែលមាននៅក្នុងតំបន់របស់អ្នក។

▶ ច្បាប់បន្តជាថ្មីរយៈពេល 6 ខែ

ចាប់ផ្តើមពីខែមករា ឆ្នាំ 2027 ច្បាប់នេះចែងថា មនុស្សពេញវ័យដែលមានអាយុចាប់ពី 19-64 ឆ្នាំនឹងទទួលបានសិទ្ធិ Medi-Cal របស់ពួកគេបន្តជាថ្មីរៀងរាល់ 6 ខែម្តង ដើម្បីធានាថាពួកគេនៅតែមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធីនេះ។

អ្នកនឹងត្រូវបានលើកលែងពីច្បាប់នេះ ក្នុងករណីដែលអ្នក៖

ជាជនជាតិដំណាក់កាត់អាមេរិក ឬជនជាតិដើមអាឡាស្កា។
មានផ្ទៃពោះ ឬធ្លាប់មានផ្ទៃពោះក្នុងរយៈពេល 12 ខែចុងក្រោយ ឬមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ការថែទាំក្រោយសម្រាលកូន។
ស្ថិតនៅក្នុងការថែទាំចិញ្ចឹមនៅថ្ងៃខួបកំណើតអាយុ 18 ឆ្នាំរបស់អ្នក ហើយមានអាយុក្រោម 26 ឆ្នាំ។

អ្នកអាចនឹងបាត់បង់ Medi-Cal របស់អ្នក

<u>ដើម្បីរក្សា Medi-Cal អ្នកត្រូវតែបំពេញតាមច្បាប់ការងារ និងការចូលរួមសហគមន៍</u>
<u>ហើយទទួលបានការត្រួតពិនិត្យសិទ្ធិទទួលបាន Medi-Cal របស់អ្នករៀងរាល់ 6 ខែម្តង</u> –
លុះត្រាតែអ្នកមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានការលើកលែង ***ដូចដែលបានពណ៌នាខាងលើ។***

ប្រសិនបើអ្នកមិនបំពេញតាមច្បាប់ទាំងនេះទេ
អ្នកនឹងទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលប្រាប់អ្នកពីអ្វីដែលអ្នកត្រូវធ្វើមុនពេលដែល Medi-Cal របស់អ្នកបញ្ចប់។ ការជូនដំណឹងនេះក៏នឹងប្រាប់អ្នកពីអ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកមិនយល់ស្របនឹងការសម្រេចចិត្តនេះ រួមទាំងសិទ្ធិប្តឹងតវ៉ារបស់អ្នក។

ប្រសិនបើអ្នកបាត់បង់ Medi-Cal ដោយសារតែអ្នកមិនបានបំពេញតាមច្បាប់ទាំងនេះ
អ្នកមិនអាចទទួលបានជំនួយហិរញ្ញវត្ថុដើម្បីបង់ថ្លៃសម្រាប់គម្រោងសុខភាពតាមរយៈ Covered California បានទេ។
នោះមានន័យថាអ្នកនឹងត្រូវបង់ថ្លៃធានារ៉ាប់រងសុខភាពថ្មីពេញលេញ។

អ្នកអាចដាក់ពាក្យសុំ Medi-Cal ម្តងទៀតនៅពេលណាក៏បាន។ ប្រសិនបើអ្នកគិតថាមានការភាន់ច្រឡំ
ឬស្ថានភាពរបស់អ្នកបានផ្លាស់ប្តូរ សូមទាក់ទងការិយាល័យ Medi-Cal ខោនធីរបស់អ្នកសម្រាប់ជំនួយ។
ស្វែងរកលេខទូរសព្ទ និងអាសយដ្ឋានរបស់ពួកគេនៅទីនេះ៖ <u>dhcs.ca.gov/COL</u>។

អ្វីដែលអ្នកត្រូវធ្វើឥឡូវនេះ

ត្រូវប្រាកដថាការិយាល័យ Medi-Cal ខោនធីរបស់អ្នកមានព័ត៌មានទំនាក់ទំនងបច្ចុប្បន្នរបស់អ្នក។
នេះរួមបញ្ចូលទាំងអាសយដ្ឋានផ្ទៃសំបុត្រ លេខទូរសព្ទ និងអាសយដ្ឋានអ៊ីមែល។ នេះជារឿងសំខាន់ណាស់។ ការិយាល័យ Medi-Cal ខោនធីរបស់អ្នកនឹងផ្ញើសំបុត្រ ផ្ញើអ៊ីមែល ឬផ្ញើសារមកអ្នកនូវព័ត៌មានបន្ថែមអំពីច្បាប់ទាំងនេះ។

ភ្ជាប់ទំនាក់ទំនងជាមួយ BenefitsCal

យើងសូមណែនាំឱ្យបង្កើតគណនីតាមរយៈ BenefitsCal.com។ BenefitsCal គឺជាគេហទំព័រផ្លូវការដែលអ្នកអាចតាមដានអត្ថប្រយោជន៍ និងឯកសាររបស់អ្នក បំពេញទម្រង់បែបបទ រាយការណ៍ការផ្លាស់ប្តូរ អាប់ឡូតឯកសារ អានការជូនដំណឹង និងច្រើនទៀត។ អ្នកក៏អាច "ជ្រើសរើសចូល" ដើម្បីទទួលបានសារជាអក្សរ និងអ៊ីមែល ដើម្បីឱ្យអ្នកអាចទទួលបានព័ត៌មានចុងក្រោយបំផុតដែលត្រូវការ ដើម្បីរក្សា Medi-Cal របស់អ្នកឱ្យនៅដំណើរការ។

ការិយាល័យ Medi-Cal ខោនធីរបស់អ្នកអាចស្នើសុំទម្រង់បែបបទបន្តជាថ្មី បង្កាន់ដៃបើកប្រាក់ និងអ្វីៗជាច្រើនទៀត។ **វាជារឿងសំខាន់ដែលអ្នកត្រូវឆ្លើយតបទៅនឹងសំបុត្រ ឬសាររបស់អ្នកនៅក្នុង BenefitsCal ឬធ្វើព័ត៌មានរបស់អ្នកទាន់ពេលវេលា ដើម្បីកុំឱ្យអ្នកប្រថុយនឹងការបាត់បង់ Medi-Cal របស់អ្នក។** អ្នកក៏អាចស្នើសុំជំនួយពីការិយាល័យ Medi-Cal ខោនធីរបស់អ្នកផងដែរ។

អ្នកតាក់តែងច្បាប់រដ្ឋ California បានវិនិយោគលើធនធានថ្មីៗ ដើម្បីជួយអ្នកពាក់ព័ន្ធនឹងច្បាប់ថ្មីទាំងនេះ។ យើងនឹងផ្ញើព័ត៌មាន និងធនធានបន្ថែមអំពីច្បាប់ទាំងនេះទៅអ្នកមុនដាច់ឆ្នាំនេះ។ វានឹងរួមបញ្ចូលគេហទំព័រ ដើម្បីជួយអ្នកស្វែងរកការងារដែលមានប្រាក់ខែ ឬការងារស្មគ្រចិត្ត ស្វែងយល់អំពីការបណ្តុះបណ្តាលការងារ ឬសាលារៀនដែលអ្នកអាចចុះឈ្មោះចូលរៀន និងអ្វីៗជាច្រើនទៀត។

មានសំណួរឬ?

- សូមទូរសព្ទ ឬទៅកាន់ការិយាល័យ Medi-Cal ខោនធីរបស់អ្នក។ សូមស្វែងរកលេខទូរសព្ទ និងអាសយដ្ឋាននៅទីនេះ៖ dhcs.ca.gov/COL។
- ចូលទៅអ៊ីនធឺណិត៖ www.dhcs.ca.gov/workrules
- សូមទូរសព្ទទៅកាន់ Medi-Cal Helpline៖ (800) 541-5555។
- បង្កើតគណនី BenefitsCal ឬចូលទៅក្នុង BenefitsCal ដើម្បីបំពេញទម្រង់បែបបទ រាយការណ៍ការផ្លាស់ប្តូរ គ្រប់គ្រងអត្ថប្រយោជន៍របស់អ្នក អាប់ឡូតឯកសារ អានការជូនដំណឹង និងអ្វីៗជាច្រើនទៀត៖ BenefitsCal.com។

សូមអរគុណ

Department of Health Care Services
រដ្ឋ California